# មនុស្ស
# សិល្បៈ
# ជំនឿ



PETER FRECKLINGTON

៤១២.
១៤

# ជុច គឿន

បរិញ្ញាប័ត្រ បុរាណវិទ្យា

មនុស្ស - សិល្បៈ
និង ជំនឿ

ជុច គឿន
វប្បធម៌ - សិល្បៈ

LIBRARY
BUDDHIST INSTITUTE

មនុស្ស - សិល្បៈ និង ជំនឿ
ផ្សាយចេញអំពីគណៈកម្មការ
ស្រាវជ្រាវសាកលវិទ្យាល័យ
វិចិត្រសិល្បៈ ។
ភ្នំពេញ ១៩៩៣

## សហការី រួមយោបល់

និងជំនួយការ

ស៊ិក ប៊ុន ហុក

ជា ពន្លក

តែ ជិន រិទ្ធ

ចាន់ ស៊ុំផា

ភៀប សុផា

ហេង ប៊ុនគុង

ភៀន ឆដាភា

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ការុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh    www.elibraryofcambodia.org

# កថាមុខ

មូលហេតុអ្វីដែលនាំអោយខ្ញុំខិតខំសរសេរស្នាដៃសាកល្បង ពិចារណានេះឡើង ? ដោយយល់ថា ការចេះចាំតែម្នាក់ឯង ពុំមានផលប្រយោជន៍អ្វីសំរាប់សមូហភាពសោះ ។ រីឯស្នាដៃមួយរបៀបនេះដែលមានខ្លឹមសារសង្កត់ធ្ងន់ទៅលើតំលៃបុរាណវិទ្យា និង មនុស្សនិយមពុំទាន់មានបោះពុម្ពជាខេមរភាសានៅឡើយទេ ។ អស់លោកអ្នកប្រាជ្ញ អ្នកនិពន្ធ ដែលបានសិក្សារួចហើយអំពីបុរាណវិទ្យានៅលើបេតិកភណ្ឌជាតិកម្ពុជា ពិតជាអ្នកត្រួសត្រាយផ្លូវផ្ដល់ប្រយោជន៍ធំធេងណាស់សំរាប់ប្រវត្តិសាស្ត្រជាតិខ្មែរ ។ សៀវភៅជាច្រើនរយក្បាល បានលាតត្រដាងពិនិត្យតែផ្នែកបុរាណវិទ្យាប៉ុណ្ណោះទេ តែថែមទាំងសិក្សាអំពីទំនៀមទំលាប់នៃការរស់នៅ វប្បធម៌ និង សង្គមធម៌ និងចូលជ្រៅទៅដល់វិស័យ ចិត្តវិទ្យា និង ជាតិពន្ធុសាស្ត្រ របស់ប្រជាជនកម្ពុជាថែមទៀត ។ ប៉ុន្តែសៀវភៅទាំងឡាយពោលខាងលើ ស្ទើរតែបោះពុម្ពជាភាសាបរទេស ដែលជាឧបសគ្គមួយរាំងពិនចំរើប្រយោជន៍ប្រជាជនជាទូទៅបាន ។ ស្នាដៃជាច្រើនទៀតដែលបោះពុម្ពជាខេមរភាសារួចហើយ របស់បណ្ឌិតសាស្ត្រាចារ្យខ្មែរជាអ្នកស្រឡាញ់វប្បធម៌ជាតិ និងចង់ពង្រឹងពន្លិបន្ថែមសំរាប់កុលបុត្រខ្មែរ បានរលាយស្ទើរបាត់ស្រពោនអស់ក្នុងរបបប្រល័យពូជសាសន៍ ក្នុងចន្លោះឆ្នាំ ១៩៧៥ - ១៩៧៩ ។

អាស្រ័យដោយមានបំណងចង់ក្សាតថ្លៃពិតរបស់វប្បធម៌ខ្មែរ ជាប្រយោជន៍សមូហភាព ដើម្បីស្វែងយល់អំពីវប្បធម៌របស់ខ្លួន តាមរយៈស្នាដៃសាកល្បងដ៏តូចនេះ ខ្ញុំខិតខំស្រាវជ្រាវដោយពុំរង់ចាំ អ្វីដែលហៅថា " សុក្រិតភាព " នោះឡើយ ។

ពេលវេលាចេះតែរសាត់បាត់ទៅដោយឥតរង់ចាំ ទន្ទឹមនោះ ឯកសារ " រស់ " មួយចំនួនដែលសេសសល់អំពីការសម្លាប់រង្គាល បានលាចាកទឹកដីអង្គរជាទីគោរព និងស្រឡាញ់ដោយនាំទៅជាមួយនូវឯកសារវប្បធម៌ដ៏មានតម្លៃជាបន្តបន្ទាប់ ។ កត្តាពោលខាងលើនេះហើយដែលជំរុញអោយខ្ញុំព្យាយាមសរសេរឯកសារនេះ ដើម្បីជាការតបស្នងសងគុណចំពោះមាតុភូមិ ។ កូនសៀវភៅដ៏តូចនេះ និងរួមចំណែកក្នុងចលនាការពារ និងកសាងមាតុភូមិស្របតាមទិសដៅរួមលើវិស័យវប្បធម៌របស់

មហាសន្និបាតបក្សប្រជាជនបដិវត្តកម្ពុជា ។ ខ្ញុំបានលើកឡើងអំពីលោកទស្សនៈចាស់ដើម្បីជាពន្លឺសំរាប់ការស្វែងយល់លោកទស្សនៈថ្មី ហើយនិងសម្បត្តិកម្មផ្ទាល់ខ្លួនខ្លះៗ ដើម្បីស្វែងយល់តើស្នាដៃបុព្វបុរសខ្មែរយើងបង្កប់ទស្សនៈលោកិយសច្ចៈធំធេងប៉ុណ្ណាទៅ នៅពីក្រោយស្នាដៃទាំងឡាយនោះ ។ បញ្ហាធំៗ ដែលបានលើកឡើងក្នុងឯកសារនេះ គឺបានមកអំពីការផ្តួចផ្តើមឡើងរបស់ព្រឹទ្ធសាស្ត្រាចារ្យ ផេង ផុន ដែលក្តីបារម្ភ ចំពោះវប្បធម៌របស់លោក ក៏ដូចជារបស់ខ្ញុំដែរ ។ ខ្ញុំបានយកគតិបណ្ឌិតរបស់លោកមកពង្រីកបន្ថែមលើការតេះតាំរបស់ខ្ញុំ និងញែកគ្នារវាងលោកទស្សនៈចាស់ និង ថ្មី សំរាប់មើលអោយឃើញអ្វីដែលជាតម្លៃរបស់ខ្មែរពិតៗ ។ ខ្ញុំយល់ថា កូនសៀវភៅនេះមិនទាន់ឆ្លើយតបទៅនឹងក្តីប្រាថ្នា របស់សិក្ខាកាមជន អ្នកប្រវត្តិសាស្ត្រ អ្នកស្រាវជ្រាវ អ្នកស្រឡាញ់វប្បធម៌ជាតិ អោយបានគ្រប់ជ្រុងជ្រោយទេ តែបើខ្ញុំរង់ចាំ ហើយខ្លាចពិន មិនសរសេរនោះ គឺមានន័យថា ខ្ញុំពុំទាន់បានតបស្នង សងគុណចំពោះប្រទេសជាតិរបស់ខ្ញុំនៅឡើយ ។

សូមឧទ្ទិសស្នាដៃនេះចំពោះ អ្នកមានគុណទាំង ជុត - ហៃ និង ប៊ឺន ភើ ដែលបានផ្តល់កំណើត និងលះបង់អ្វីៗទាំងអស់ ដើម្បីបង្កលទ្ធភាពអោយខ្ញុំបានសិក្សារៀនសូត្រ ហើយនិងចំពោះព្រលឹងបុព្វបុរសដែលបន្សល់ទុកកេរ្តិ៍ដំណែលដ៏ស្អេកស្កះ សំរាប់ផ្តល់តម្លៃដល់ប្រទេសកម្ពុជា លើឆាកអន្តរជាតិ ។ ក្នុងអវសានកថានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះព្រឹទ្ធសាស្ត្រាចារ្យ ផេង ផុន និងសហការីរួមការងារក្នុងសមាគមវប្បធម៌តៃប៉ូយ ដែលបានជួយធ្វើអោយសំរេចឯកសារនេះឡើង ហើយក្នុងនោះក៏មានភរិយាខ្ញុំ នាង គាន់ ធុំ ដែលជាអ្នកបានសិក្សារៀនសូត្រក្នុងជំនាញជាមួយគ្នា បានចូលរួមយោបល់ដើម្បី ជួយធ្វើអោយកូនសៀវភៅ នេះមានកំណើតឡើងដែរ ។

ភ្នំពេញ , ថ្ងៃ ទី ២៤ ខែ មិថុនា ឆ្នាំ ១៩៩៨

អ្នកស្រាវជ្រាវ

ជុត កៀន

# វប្បធម៌ សិល្បះ

## ជំពូក ១

## សិក្សាបុរាណវិទ្យា

### I . អ្វីទៅហៅថា វិមានប្រវត្តិសាស្ត្រ ៖

វិមានប្រវត្តិសាស្ត្រ គឺ ជាសំណង់ " អចលនវត្ថុ " ឬ ជាចលនវត្ថុ ដែលជាកម្មសិទ្ធរបស់សម្ហូហភាពសាធារណៈ ឬ ឯកជនដែលត្រូវបានគេដាក់អោយនៅក្រោមច្បាប់ពិសេស អាស្រ័យដោយវាមានប្រយោជន៍ជាប្រវត្តិសាស្ត្រ ឬ សិល្បះ បន្ទាប់ពីមានជានរិយកម្មថ្នៃករដ្ឋបាល ធ្វើឡើងដើម្បីធានាដល់ការថែរក្សាទុកនៃសម្បត្តិនេះ ។

បុរាណវិទ្យាជាវិទ្យាសាស្ត្រមួយ ដែលសិក្សាទៅលើអំពីអតីតកាលតាមរយៈប្រាង្គប្រាសាទ ហើយនិងសិក្សាអំពីបុរេប្រវត្តិសាស្ត្ររបស់ប្រជាជាតិ ។ វិទ្យាសាស្ត្រនេះឆ្លុះបញ្ចាំងអារ្យធម៌ តាមរយៈវិទ្យាសាស្ត្រដទៃជាច្រើនទៀត ដូចជា នរវិទ្យា ជាតិពន្ធុវិទ្យា ជាសាណវិទ្យា ភូគព្ភសាស្ត្រ ។ល។ ដែលជំនួយអោយអ្នកសិក្សាយល់អ្វីដែលជាគ្រឹះ នៃអារ្យធម៌របស់មនុស្ស ។ បុរាណវិទូជាច្រើនបានសិក្សាអំពីអារ្យធម៌ខ្មែរនាម័យថ្មំរំលីង ដូចជាសំរោងសែន ម្លូព្រៃ អន្លង់ព្រាវ[1] ហើយនិងល្អាងស្ពាន។ ស្នាទីយ៍ទាំង ក្រោយនេះ បានប្រាប់អាយុចំនួន ៩២៥០ ឆ្នាំ មុនគ្រិស្តសករាជរបស់ប្រជាជនកម្ពុជា ដែលចេះប្រើប្រាស់ ត្នម ភ្នាំង សំរាប់ចំអិនម្ហូបអាហារ ។

សេចក្តីសន្និដ្ឋានកំណត់ថា ប្រជាជនកម្ពុជា បានរស់នៅក្នុងល្អាងស្ពាននេះតាំងពីប្រមាណ ៩០០០ ឆ្នាំមុនគ្រិស្តសករាជនោះមកម្លេះ[2] ។ វត្ថុតាំងជាច្រើនទៀត ដូចជាធានរបស់ស្ថានីយ៍ សំរោងសែន ពូថៅថ្ម ផ្លែកណ្តៀវ គ្រឿងអំពិសរិទ្ធ គ្រឿងអលង្ការ នាកាតខាងដើមនៃប្រវត្តិសាស្ត្រ ។ល។ ចាប់តាំងពីពាក់កណ្តាលសតវត្សទី ១៩ មកបណ្តាលោកអ្នកប្រាជ្ញ ស្លាបត្យករ បុរាណវិទូ បានបង្ករើកទ្វាជាច្រើនដើម្បីកត់ត្រាអ្វីដែលយើងហៅថា វិមានប្រវត្តិសាស្ត្រ ដែលត្រូវបានចុះបញ្ជីចត្រេចហើយៗដាក់អោយនៅក្រោមច្បាប់របស់រដ្ឋ ដើម្បីធានាដល់ការថែរក្សាជូនជុំ

---

(១) អន្លង់ ក្រញូង អន្លង់ផ្កា ស្ទឹង ខេត្តកំពង់ធំ សំរោងសែន

(២) របាយការណ៍ បុរេប្រវត្តិល្អាងស្ពាន ៖ ខេត្តបាត់ដំបង - ប្រទេសកម្ពុជា ដោយ ស៊ុំស៊ុន និង រ៉ូឡង់មូរ៉ែ - (ព្រះរាជបណ្ឌិត្យ ...បុរាណវិទ្យា និង ...) - ...ក្រចុំ - ...លេខ ២ ...១៩៦៨




កម្ពុជា : ផែនទីរូប និង មនុស្ស

ខ្សែគំនូសធំ : បង្ហាញជួរភ្នំ ។ គំនូសដាច់បង្ហាញព្រំប្រទល់ ។ ខ្សែគំនូសជាចំណុច : បង្ហាញព្រំខណ្ឌតំបន់ទឹកលិចរៀងរាល់ឆ្នាំ ។ ខ្សែគំនូសជាប់ តូច ជុំវិញបឹងធំ : បង្ហាញទីដីមានប្រជាជនច្រើន ដកស្រង់អំពី - ឌិល ដែរត៍ ។

និងដាក់តាំងក្នុងសារមន្ទីរ ។ ទោះបីនេះ យើងបានសិក្សា បុរាណវិទ្យាស្របទៅតាមទស្សនៈរួមរបស់ ហ្វីបាច ដែលលោកបាន កត់សំគាល់ថា " គេមិនបានកសាងប្រាង្គប្រាសាទឡើង ដើម្បីថ្វាយអាទិទេពទេ ក៏ប៉ុន្តែគេបានកសាងប្រាសាទ ដើម្បីតំណាងស្ថាបត្យកម្ម នេះហើយជាទូទៅមានតម្លៃសំរាប់សិល្បៈ " ។ ជាការពិតណាស់ នៅក្នុងសតវត្សទី ១៣ សំណង់ជាច្រើនសាងឡើងដើម្បីជាបន្ទោបាយសំដែងប្រាប់អ្វីដែលមាននៅក្នុងជីវិតប្រជាជន ដូចជាសេចក្តីសប្បាយ និង សុភមង្គល ការឈឺចាប់ និងទុក្ខព្រួយ អំពើល្អ និង អាក្រក់ ...

១.១. តួលេខ នៃវិមានប្រវត្តិសាស្ត្រដកស្រង់អំពីបញ្ជីសារពើភណ្ឌចុះបញ្ជីរួចហើយ÷ [៣]

| ល.រ | បណ្តាខេត្ត | ចំនួន | សំគាល់ផ្សេងៗ |
|---|---|---|---|
| ១ | - បាត់ដំបង ... | ៣៨៤ | |
| ២ | - សៀមរាប ... | ២៥២ | |
| ៣ | - កំពង់ធំ ... | ១៦៤ | |
| ៤ | - កំពត ... | ៨ | |
| ៥ | - កណ្តាល - ភ្នំពេញ... | ៩ | |
| ៦ | - កំពង់ចាម ... | ៤៨ | |
| ៧ | - កំពង់ឆ្នាំង ... | ៩ | |
| ៨ | - កំពង់ស្ពឺ ... | ៦ | |
| ៩ | - ក្រចេះ ... | ១២ | |
| ១០ | - ព្រៃវែង ... | ២៧ | |
| ១១ | - ពោធិសាត់ ... | ៧ | |
| ១២ | - ស្ទឹងត្រែង ... | ៥៤ | |
| ១៣ | - ស្វាយរៀង ... | ៦ | |
| ១៤ | - តាកែវ ... | ៣៤ | |
| | | សរុប : ១០៧០ | |

---

(៣) នាយកដ្ឋាន ម.ស.ន. : បញ្ជីវិមានប្រវត្តិសាស្ត្រ សន្និបាតប្រចាំឆ្នាំ ១៩៩០

១.២. សិល្បារម្មណ៍សាស្ត្រម៉ាក្សនិយម ពិចារណាសិល្បៈទុកដូចជាប្រព័ន្ធនៃបណ្ដាទំរង់ទាំងឡាយនៃនិម្មិតកម្មសិល្បៈ ដែលបានរៀបចំឡើងទៅតាមក្រិត្យក្រមទាំងឡាយយ៉ាងត្រឹមត្រូវណាស់។ គ្មានថានិយកម្ម ឯកភាពអំពីសិល្បៈទេ គឺមិនទាន់គេអាចស្រង់យកគោលការណ៍ខ្លះ អំពីការបែងចែកសិល្បៈជាក្រុមៗ ដែលបង្ហាញបណ្ដាចំណុចផ្សេងៗនានា។ ថាននិយកម្ម[៦] ដែលចែកសិល្បៈជា ៣ ក្រុម ដោយញឹកញាប់បំផុតនោះគឺ :

១.២.១ - សិល្បៈអចលៈ " ស្ដាទិក " ក្នុងសិល្បៈនេះ រូបភាព " ចំនិត ភាសា និងការស្រមៃ " មួយបានគេដាក់អោយនៅស្ងៀមក្នុងអវកាស ហើយមិនអភិវឌ្ឍន៍ទៅតាមពេលវេលា ។ សិល្បៈប្រភេទទី ១ នេះគឺមានជាអាទិ សិល្បៈសូនរូប និង ស្ថាបត្យកម្ម ។

១.២.២ - សិល្បៈ ចលៈ " ឌីណាមិក " ក្នុងសិល្បៈនេះ រូបភាពមួយវិវត្តទៅតាមពេលវេលាមួយជាកំណត់ ហើយគ្មានអត្ថិភាព អវកាសទេ ។ សិល្បៈប្រភេទ ទី ២ នេះ គឺ អក្សរសិល្ប៍ ភ្លេង ។

១.២.៣ - សិល្បៈអចលៈ-ចលៈ ក្នុងសិល្បៈនេះ រូបភាពមួយ គឺ ជាការរួមទំរង់ទាំងពីរខាងលើ ។ សិល្បៈប្រភេទ ទី ៣ នេះ គឺរាល់សិល្បៈនៃទស្សនីយភាព ។

តើមូលហេតុអ្វីដែលនាំអោយប្រជាជនកម្ពុជា កសាងវិមានដែលមានតម្លៃប្រវត្តិសាស្ត្រ - សិល្បៈនេះឡើង ? ការសិក្សាស្រាវជ្រាវទៅលើមនុស្សតាំងពីអតីតកាលដ៏យូរលង់ មកោល គឺតាំងពីពូជសាសន៍អេកអង់ធ្រាកតាល់ បករសល់ ក្រូម៉ាញ៉ុង និងត្រីម៉ាល់ឌី បានបង្ហាញប្រាប់ថា សិល្បៈកើតចេញអំពីការច្នៃប្រឌិតបច្ចេកទេសផ្សេងៗ សំរាប់ជំនីជីវភាពប្រចាំថ្ងៃ របស់មនុស្ស ហើយនិងជំនឿជំបូងៗទៅលើលទ្ធិជីវចល " ព្រលឹង " ។ ម្យ៉ាងទៀត យើងក៏សង្កេតឃើញផងដែរថា រាល់ទំរង់សិល្បៈ គំនូរនិងកើតចេញអំពីការគូសព្រាងទុក ។ ពីព្រោះការគូសព្រាងទុក គឺជាការសង្កេតដោយត្រង់ដែលៗ ល៉ែងដក់ចិត្តរបស់អ្នកនិពន្ធ គឺ សិល្បៈករ ។ ល ។ ទៅលើធម្មជាតិដែលរស់រវើក នៅជុំវិញខ្លួនយើងហើយនិងភាពផែនរបស់ជាតុក្ខតធម្មជាតិ ។ ដោយឡែកចេញអំពីនេះ សិល្បៈ ប្រាកដនិយមក៏បានចាប់កំណើតឡើង ។ ហើយជាវឌ្ឍនភាពអភិវឌ្ឍ ទៅកាន់សិល្បៈប្រភេទអរូបិយ៍ ប្រភេទសិល្បៈចំព្រាញ " សេម៉ាទិស " ហើយនៅក្នុងក្រោយវាវិវត្តទៅរកប្រភេទនិមិត្តរូប ។ តាំងតាំងពីមនុស្សចេះកប់ខ្មោច យើងឃើញមានស្ថាបត្យកម្មដែរ ដូចជា ម៉ុងហ៊ីរ និង ឌុលម៉ែន ដែលគេសាងឡើងសំរាប់បញ្ចុះសាកសព ហើយនិងការកសាងជាប្រាសាទសាជី នៅប្រទេសអេស៊ីប កសាងផ្នូរខ្មោចធំៗដោយពួកនី

(៦) តាមតាត់ខ្ញុំ